ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ ០០៣ អពដ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

L202012240411 | TD2049

ថ្ងៃចន្ទ ៥រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១

**សូមគោរពជូន**

- **ឯកឧត្តម លោកជំទាវ លោក អគ្គនាយករងទាំងអស់**
- **លោកប្រធាននាយកដ្ឋានថ្នាក់កណ្តាលទាំងអស់**
- **លោកប្រធានទីចាត់ការពន្ធដាររាជធានីភ្នំពេញ**
- **លោកនាយកសាលាជាតិពន្ធដារ**
- **លោកប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់**

**កម្មវត្ថុ** ៖ ស្តីពីការអនុវត្តសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា (ជុំទី៧) អំពីវិធានការបន្ថែម ដើម្បីបន្តគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗនៃសេដ្ឋកិច្ច នៅក្នុងបរិការណ៍វិបត្តិ, ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩ និងការផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យមានលក្ខណៈឯកភាពតែមួយ។

**យោង** ៖ សេចក្តីប្រកាសព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីវិធានការបន្ថែម ដើម្បីបន្តគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗនៃសេដ្ឋកិច្ច នៅក្នុងបរិការណ៍វិបត្តិ, ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩ (ជុំទី៧, ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោកជំទាវ លោក អគ្គនាយករង លោកប្រធាននាយកដ្ឋានថ្នាក់កណ្តាល លោកប្រធានទីចាត់ការពន្ធដាររាជធានីភ្នំពេញ លោកនាយកសាលាជាតិពន្ធដារ និងលោកប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ជ្រាបថា រាជរដ្ឋាភិបាលកម្ពុជាបានណែនាំអំពីវិធានការបន្ថែម ដើម្បីបន្តគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗ នៃសេដ្ឋកិច្ច នៅក្នុងបរិការណ៍វិបត្តិ, ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩ ជាពិសេសការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យអាកាសចរណ៍ និងវិស័យទេសចរណ៍។ ដូចនេះ ដើម្បីឱ្យការផ្តល់សេវាជូនអ្នកជាប់ពន្ធមានភាពងាយស្រួល រហ័ស និងមានលក្ខណៈឯកភាពតែមួយ សូមឯកឧត្តម លោកជំទាវ លោក អគ្គនាយករង លោកប្រធាននាយកដ្ឋាន លោកប្រធានទីចាត់ការពន្ធដាររាជធានីភ្នំពេញ លោកនាយកសាលាជាតិពន្ធដារ និងលោកប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ចូលរួមអនុវត្ត ផ្សព្វផ្សាយនិងណែនាំដល់មន្ត្រីក្រោមឱវាទ នូវវិធានការបន្ថែម ដូចខាងក្រោម៖

- បន្តលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ (អាករលើតម្លៃបន្ថែម, ប្រាក់រំដោះពន្ធលើប្រាក់ចំណូល, ពន្ធលើប្រាក់បៀវត្ស, ពន្ធលើអត្ថប្រយោជន៍បន្ថែម, ពន្ធកាត់ទុក, អាករពិសេសលើទំនិញ និងសេវាមួយចំនួន, អាករសម្រាប់បំភ្លឺសាធារណៈ និងអាករលើការស្នាក់នៅ) ចំពោះសណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន, និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី

L202012240411 | TD2049

ភ្នំពេញ, ខេត្តសៀមរាប, ខេត្តព្រះសីហនុ, ខេត្តកែប, ខេត្តកំពត, ក្រុងបាវិត, និងក្រុងប៉ោយប៉ែត សម្រាប់រយៈពេល ០៣ខែ បន្ថែមទៀត ដោយគិតចាប់ពីខែមករា រហូតដល់ខែមីនា ឆ្នាំ២០២១។

- បន្តលើកលែងការបង់ពន្ធប៉ាតង់ និងពន្ធតែមប្រ៍សារពើពន្ធ (ពន្ធលើស្លាកយីហោ) ចំពោះក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ និងប្រតិបត្តិករក្នុងវិស័យទេសចរណ៍ដទៃទៀត។ ក្នុងករណីនេះ ត្រូវណែនាំអ្នកជាប់ពន្ធឱ្យធ្វើការប្រកាសពន្ធ ដោយប្រាក់ពន្ធជាបន្ទុករបស់រដ្ឋ និងបោះពុម្ពប័ណ្ណពន្ធប៉ាតង់សម្រាប់ឆ្នាំ២០២១ របស់ខ្លួន។
- អ្នកជាប់ពន្ធក្នុងវិស័យទេសចរណ៍ដូចជា៖ សណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានីភ្នំពេញ, ខេត្តសៀមរាប, ខេត្តព្រះសីហនុ, ខេត្តកែប, ខេត្តកំពត, ក្រុងបាវិត, និងក្រុងប៉ោយប៉ែត ត្រូវបានលើកលែងពន្ធគ្រប់ប្រភេទ (ពន្ធលើប្រាក់ចំណូល ឬពន្ធអប្បបរមា) តែសហគ្រាសត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២០ យ៉ាងយឺតបំផុតឱ្យបានមុនដំណាច់ខែមីនា ឆ្នាំ២០២១។
- បន្តលើកលែងការបង់ពន្ធអប្បបរមា (Minimum Tax) សម្រាប់រយៈពេល ០៣ខែ បន្ថែមទៀត ចាប់ពីខែមករា រហូតដល់ខែមីនា ឆ្នាំ២០២១ ជូនដល់ក្រុមហ៊ុនអាកាសចរណ៍ ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្នុងរយៈពេលនេះ មិនមានការតម្រូវឱ្យបង់ពន្ធលើប្រាក់រំដោះពន្ធលើប្រាក់ចំណូល (Prepayment Of Income Tax) ទេ។
- បន្តលើកលែងពន្ធប្រថាប់ត្រាសម្រាប់អ្នកទិញផ្ទះដែលមានតម្លៃទាបជាង ឬស្មើប្រាំពីរម៉ឺនដុល្លារអាមេរិក ដោយគិតចាប់ពីខែមករា ឆ្នាំ២០២១ ដល់ដំណាច់ខែធ្នូ ឆ្នាំ២០២១ បានទិញពីក្រុមហ៊ុនអភិវឌ្ឍលំនៅឋានដែលបានចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬនៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ហើយបានចុះបញ្ជីពន្ធដារ។
- ការបន្ធូរបន្ថយការអនុវត្តពន្ធកាត់ទុកលើការប្រាក់សម្រាប់អ្នកផ្តល់កម្ចីក្នុងស្រុក និងក្រៅស្រុក (Withholding Tax) ចំពោះធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ សម្រាប់កម្ចីដូចខាងក្រោម៖

  ក. កម្ចីថ្មី វៀរលែងតែប្រាក់កម្ចីចាស់ ឬការស្នើសុំបន្ថែមលើប្រាក់កម្ចីចាស់ត្រូវ៖

  - អនុវត្តពន្ធកាត់ទុកតាមអត្រា ៥ ភាគរយ ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជន (ការខ្ចីពីប្រទេសដែលមាន DTA និងប្រទេសដែលមិនមាន DTA) សម្រាប់ឆ្នាំ ២០២១។
  - អនុវត្តពន្ធកាត់ទុកតាមអត្រា ១០ ភាគរយ ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជន (ការខ្ចីពីប្រទេសដែលមាន DTA និងប្រទេសដែលមិនមាន DTA) សម្រាប់ឆ្នាំ ២០២២។
  - អនុវត្តពន្ធកាត់ទុកតាមអត្រាធម្មតាស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជន សម្រាប់ឆ្នាំ២០២៣ តទៅ។

  ខ. កម្ចីចាស់ ដែលនៅមានសុពលភាព ត្រូវ៖

  - អនុវត្តពន្ធកាត់ទុកតាមអត្រា ១០ ភាគរយ ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជន (ការខ្ចីពីប្រទេសដែលមាន DTA និងប្រទេសដែលមិនមាន DTA) សម្រាប់ឆ្នាំ ២០២១។
  - អនុវត្តពន្ធកាត់ទុកតាមអត្រាធម្មតាស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជន សម្រាប់ឆ្នាំ២០២២ តទៅ។

L202012240411 | TD2049

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក អគ្គនាយករង លោកប្រធាននាយកដ្ឋានថ្នាក់កណ្តាល លោកប្រធានទីចាត់ការពន្ធដាររាជធានីភ្នំពេញ លោកនាយកសាលាជាតិពន្ធដារ និងលោកប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ចូលរួមអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម លោកជំទាវ លោក អគ្គនាយករង លោកប្រធាននាយកដ្ឋានថ្នាក់កណ្តាល លោកប្រធានទីចាត់ការពន្ធដាររាជធានីភ្នំពេញ លោកនាយកសាលាជាតិពន្ធដារ និងលោកប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រ ពីខ្ញុំ

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

Grant Thornton (Cambodia) Limited
Unofficial translation

# KINGDOM OF CAMBODIA
# NATION RELIGION KING

**MINISTRY OF ECONOMY AND FINANCE**
**GENERAL DEPARTMENT OF TAXATION**
No. 006 GDT

Phnom Penh, 04 January 2021

TO

- HIS/HER EXCELLENCY DEPUTY GENERAL DIRECTOR
- DIRECTOR OF ALL CENTRAL DEPARTMENT
- DIRECTOR OF PHNOM PENH MUNICIPAL TAX OFFICE
- DIRECTOR OF NATIONAL TAX SCHOOL
- DIRECTOR OF ALL PROVINCIAL-KHAN TAX BRANCH

Objective: On the implementation of the instruction of the Royal Government of Cambodia (round 7) on additional measures in order to continue managing impacts on key sectors of the economy in the context of the operation to restore and stimulate Cambodia's economic growth after the crisis of covid-19 and the provision of unified services to taxpayers.

Reference: Press release on the instruction of Royal Government of Cambodia on additional measures in order to continue managing impacts on key sectors of the economy in the context of the operation to restore and stimulate Cambodia's economic growth after the crisis of covid-19 (round 7, dated 23 December 2020).

Pursuant to above objective and reference, I would like to inform you that the Royal Government of Cambodia has introduced additional measures in order to continue managing impacts on key sectors of the economy in the context of the operation to restore and stimulate Cambodia's economic growth after the crisis of covid-19, especially tax incentives on aviation and tourism sector. Therefore, in order for the provision of services to taxpayers to be easy, fast and unified, please participate in implementation and instruction to subordinates on the additional measures as follows:-

- Continue to exempt all types of monthly taxes (Value Added Tax, Prepayment of Tax on Income, Tax on Salary, Tax on Fringe Benefits, Withholding Tax, Specific Tax on Certain Merchandises and Services, Public Lighting Tax, and Accommodation Tax) for hotels, guesthouse, restaurant, and tour agent companies registered with the General Department of Taxation ("GDT") and having business activity in Phnom Penh, Siem Reap, Preah Sihanouk Province, Kep Province, Kampot Province, Bavet town, and Poipet town for an additional 03 months starting from January to March 2021.

- Continue to exempt Patent Tax and Stamp Tax (signboard tax) for tour agent Company and other tour operators. In this case, the taxpayers shall be instructed to declare tax as state-charge and issue their patent tax for 2021.

- Taxpayers in tourism sector such as hotel, guesthouse, restaurant, and tour agent companies registered with the GDT and having business activity in Phnom Penh, Siem Reap, Preah Sihanouk Province, Kep Province, Kampot Province, Bavet town, and Poipet town shall be exempted from all types of taxes (tax on income or minimum tax). However, the enterprise shall submit annual tax on income return for the year 2020 by March 2021 at the latest.

- Continue to exempt minimum tax for an additional 03 months starting from January to March 2021 for Airlines Company registered in the Kingdom of Cambodia, which during this period are not required to pay Prepayment of Income Tax.

- Continue to exempt stamp tax for person who buys house with a value of less than or equal to USD 70,000, starting from January 2021 until the end of December 2021, from a housing development company registered with the Ministry of Economy and Finance or at Provincial Department of Economy and Finance and also registered with the GDT.

- Relieve the implementation of withholding tax on interest for local and foreign lenders for banks and microfinance institutions for the following loans:

    A. New loan, except old loan or top-up on old loan:

        - Implement withholding tax rate 5% for the interest paid to resident and non-resident taxpayers (borrowing from countries with DTA and non-DTA) for the year 2021.
        - Implement withholding tax rate 10% for the interest paid to resident and non-resident taxpayers (borrowing from countries with DTA and non-DTA) for the year 2022.
        - Implement normal withholding tax according to the Law on Taxation for the interest paid to resident and non-resident for the year 2023 onward.

    B. Old loans that are still valid:

        - Implement withholding tax rate 10% for the interest paid to resident and non-resident taxpayers (borrowing from countries with DTA and non-DTA) for the year 2021.
        - Implement normal withholding tax according to the Law on Taxation for the interest paid to resident and non-resident for the year 2022 onward.

As mentioned above, please kindly jointly implement this decision effectively.

Please kindly accept my highest appreciation.

Royal Government Delegate in charge as
Director General of the General Department of Taxation
Signed and Sealed

Kong Vibol